# មេរៀនទី ១២៨៖ គ្រីស្ទបរិស័ទជួយគ្នាទៅវិញទៅមក

## ទំនុកដំកើង២៣ កិច្ចការ២៖៤២-៤៧

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/BndzEmwRm04

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/K4mMpNfTDzo

**គោលបំណង៖ ព្រះចង់ឲ្យយើងជួយគ្នាទៅវិញទៅមក។**

**ខគម្ពីរចងចាំ៖ កិច្ចការ ២៖៤២** *"អ្នកទាំងនោះក៏នៅតែព្យាយាមក្នុងសេចក្តីបង្រៀនរបស់ពួកសាវ័ក ហើយក្នុងសេចក្តីប្រកបគ្នា ព្រមទាំងការកាច់នំបុ័ង និងសេចក្តីអធិស្ឋានផង។"*

**ចំរៀង** ( *យូធូបលីង* )៖

១. គឺជាការល្អ https://youtu.be/8K1SSE4KGYM

២. ចូរទៅបណ្តុះបណ្តាល https://youtu.be/_VLCbTBVyIY

៣.ព្រះអម្ចាស់យើងល្អណាស់ https://youtu.be/JUMy8rZvqjY

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត «បាល់បោះ»**



សម្ភារៈដែលត្រូវការ៖ បាល់២ ឬផ្លែឈើមូលៗ

១. ចែកកុមារជា២ក្រុម។

ឲ្យពួកគេឈរជាជួរតាមក្រុមនៅកណ្តាលថ្នាក់រៀន ដោយកន្ទែកជើង

២.កុមារដែលនៅមុខគេត្រូវរមៀលបាល់ពីមុខទៅ ក្រោយ នៅចន្លោះជើងកុមារទាំងអស់។

៣.កុមារដែលនៅក្រោយគេត្រូវចាប់បាល់ហើយរត់មកខាងមុខ គេរួចចាប់ផ្តើមរមៀលបាល់នោះទៅក្រោយវិញ ហើយកុមារដែលនៅក្រោយគេ ត្រូវចាប់បាល់រួចរត់ មកខាងមុខ។ ធ្វើបែបនេះដដែលៗ រហូតដល់កុមារគ្រប់គ្នាបានរត់មកមុខគ្រប់ៗគ្នា

៤. ក្រុមណាដែលអាចលេងចប់មុនគេក្រុមនោះជាអ្នកឈ្នះ

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ការសហការគ្នាគឺពិតជាមាន សារៈសំខាន់ណាស់ក្នុងការលេងល្បែងនេះ។ ក៏ដូចគ្នានេះដែរ ពួកយើងគឺត្រូវសហការគ្នា និងជួយមើល ថែបងប្អូនប្រុសស្រីក្នុងព្រះគ្រីស្ទទៅវិញទៅមក។

**៤. ការណែនាំមេរៀន**

ព្រះបានបង្កើតអ្វីគ្រប់យ៉ាងទាំងអស់ដូចដែលយើងឃើញ - ដើមឈើ សត្វ បក្សី ទន្លេ ផ្កា និងរបស់ស្រស់ស្អាតជាច្រើនទៀត។ ព្រះក៏បានដាក់បុគ្គលមួយចំនួននៅក្នុងជីវិតរស់នៅរបស់យើង ដើម្បីជួយយើងក្នុងការលូតលាស់ផងដែរ។ ហើយព្រះក៏ចង់ឲ្យយើងចេះជួយអ្នកដទៃផងដែរ! តោះសូមឲ្យយើងបានរៀនអំពីពួកសិស្ស ដែលបានជួយគ្នាទៅវិញទៅមកបន្ទាប់ពីព្រះយេស៊ូវបានយាងទៅឯស្ថានសួគ៌វិញ!

**៥. រឿងនៅក្នុងព្រះគម្ពីរ**

បន្ទាប់ពីព្រះយេស៊ូវបានសុគត់ និងរស់ឡើងវិញ ហើយយាងទៅឯស្ថានសួគ៌វិញ គឺពួកសាវ័ក និងអ្នកដែលជឿលើព្រះយេស៊ូវទាំងអស់បានពេញដោយព្រះវិញ្ញាណបរិសុទ្ធ។ ពួកគេគឺមានភាពក្លាហានក្នុងការប្រាប់អ្នកដទៃអំពីព្រះយេស៊ូវ និងពីរបៀបដែលព្រះបានសង្គ្រោះពួកយើងដោយការជឿលើព្រះយេស៊ូវដែលបានសុគត់នៅលើឈើឆ្កាង ហើយមានព្រះជន្មរស់ឡើងវិញដើម្បីលោះបាបយើង! ពួកសិស្សនិងអ្នកជឿព្រះជាច្រើនទៀតបានមើលថែគ្នាទៅវិញទៅមកផងដែរ។ តើពួកគេអាច មើលថែគ្នាបានដោយរបៀបណា?

ព្រះគម្ពីរ**កិច្ចការ ២៖៤២** បានប្រាប់យើងថា អ្នកទាំងនោះក៏នៅតែព្យាយាមក្នុងសេចក្តីបង្រៀនរបស់ពួកសាវ័ក។ ពួកយើងអាចរៀនបន្ថែមទៀតអំពីព្រះយេស៊ូវតាមរយៈព្រះគម្ពីរ, ប៉ុន្តែអ្នកជឿព្រះនៅសម័យនោះគឺមិនមានព្រះគម្ពីរសញ្ញាថ្មីនោះទេ។ ដូច្នេះពួកគេគឺអាចរៀនបន្ថែមអំពីព្រះបានតាមរយៈពួកសាវ័ក។ ពួកសាវ័កបានបង្រៀនគ្រីស្ទបរិស័ទ ដូច្នេះពួកគេអាចរីកចម្រើនក្នុងព្រះបាន។

ព្រះគម្ពីរ**កិច្ចការ២៖៤២** ក៏បានប្រាប់យើងដែរថា ពួកគេគឺប្រកបគ្នា ព្រមទាំងការកាច់នំប៉័ង និងអធិស្ឋានជាមួយគ្នាផងដែរ។ នេះគឺមានន័យថា ពួកគេគឺជាមិត្តល្អនឹងគ្នា ហើយពួកគេគឺញ៉ាំជាមួយគ្នា ជជែកជាមួយគ្នា និងនិយាយទៅកាន់ព្រះជាមួយគ្នា។ តើអ្នកបានចំណាយពេលជាមួយគ្រីស្ទបរិស័ទផ្សេងទៀត ហើយអធិស្ឋានជាមួយពួកគេដែរឬទេ? ព្រះចង់ឲ្យគ្រីស្ទបរិស័ទមើលថែគ្នា តាមរយៈការចំណាយពេលជាមួយគ្នា។

ព្រះគម្ពីរ**កិច្ចការ ២៖៤៣** បាននិយាយថា “គ្រប់គ្នាកើតមានចិត្តកោតខ្លាច ហើយមានការអស្ចារ្យ និងទីសំគាល់ជាច្រើនកើតមក ដោយសារពួកសាវ័កដែរ។”ព្រះគឺពោរពេញដោយព្រះចេស្តា ហើយទ្រង់គឺអាចធ្វើអ្វីៗ បានគ្រប់យ៉ាងតាមរយៈយើងទាំងអស់គ្នា។ ព្រះគឺបានធ្វើនូវរឿងអស្ចារ្យជាច្រើនតាមរយៈ ពួកសាវ័ក (ពួកសិស្ស) និងគ្រីស្ទបរិស័ទផ្សេងទៀត ដែលចាប់ផ្តើមស្វែងយល់ពីព្រះដ៏អស្ចារ្យរបស់យើង។

ព្រះគម្ពីរ **កិច្ចការ ២៖ ៤៤-៤៦** ក៏បានពន្យល់ពួកយើងដែលថា គ្រីស្ទបរិស័ទទាំងអស់បានចែករំលែកនូវអ្វីដែលពួកគេមាន ដូច្នេះពួកគេគ្រប់គ្នាគឺមានអាហារហូបចុកគ្រប់គ្រាន់ ហើយក៏អាចទទួលបាននូវអ្វីដែលពួកគេត្រូវការផងដែរ។ គ្រីស្ទបរិស័ទគឺពិតជាបានមើលថែគ្នាទៅវិញទៅមកមែន។ តើអ្នកគឺជាបុគ្គលដែលមានចិត្តល្អក្នុងការចែករំលែកនូវរបស់ផ្ទាល់ខ្លួនដែរឬទេ?

ព្រះគម្ពីរ **កិច្ចការ ២៖៤៧** បាននិយាយថា មនុស្សគ្រប់គ្នាគឺតែងតែសរសើរតម្កើងដល់ព្រះជាម្ចាស់។ នៅពេលដែលពួកគេធ្វើការសរសើរតម្កើងព្រះគឺពួកគេតែងតែប្រាប់ទ្រង់ថា ព្រះអង្គអស្ចារ្យប៉ុនណា និងថាតើពួកគេស្រលាញ់ទ្រង់ប៉ុនណា។ នៅពេលអ្នកដែលមិនមែនជាគ្រីស្ទបរិស័ទបានឃើញពីរបៀបដែលគ្រីស្ទបរិស័ទមើលថែគ្នាទៅវិញទៅមក និងការអស្ចារ្យជាច្រើនដែលបានកើតឡើងនៅក្នុងព្រះវិហារនោះ ពួកគេក៏ចង់ចូលរួមនិងក្លាយទៅជាអ្នកជឿផងដែរ! ព្រះគម្ពីរបាននិយាយដូច្នេះថា “ព្រះអម្ចាស់ទ្រង់ក៏បន្ថែមនូវអស់អ្នក ដែលកំពុងតែបានសង្គ្រោះរាល់តែថ្ងៃទៅក្នុងពួកជំនុំថែមទៀត។” នេះគឺជាដំណឹងដ៏អស្ចារ្យ!

សូមឲ្យយើងទាំងអស់គ្នាបានមើលថែគ្នាទៅវិញទៅមកនៅព្រះវិហារ និងនៅក្នុងជីវិតរស់នៅរបស់យើង ដូច្នេះ យើងអាចលើកទឹកចិត្តដល់អ្នកឯទៀតឲ្យមកចូលរួមនៅក្នុងព្រះវិហារ និងទទួលបានការសង្គ្រោះដែរ។ ចូលចាំថាព្រះស្រលាញ់ពួកយើង ហើយទ្រង់ចង់ឲ្យយើងបង្ហាញសេចក្តីស្រលាញ់នោះ ទៅកាន់អ្នកដទៃផងដែរ!

## ៦. សំនួរពិភាក្សា

១.តើក្រុមជំនុំដំបូងគេដែលជឿលើព្រះបានបង្ហាញការដែលពួកគេមើលថែគ្នាទៅវិញទៅមកដូចម្តេចខ្លះ?
*(ស្វែងយល់ពីព្រះជាមួយគ្នា ការប្រកបគ្នា ហូបអាហារជាមួយគ្នា អធិស្ឋានជាមួយគ្នា ចែករំលែកនូវអ្វីគ្រប់យ៉ាង និងសរសើរតម្កើងព្រះជាមួយគ្នា)*
២. តើមានអ្វីខ្លះដែលក្រុមជំនុំរបស់អ្នកអាចធ្វើបានដើម្បីបង្ហាញពីការមើលថែគ្នាទៅវិញទៅមកនោះ?
*(ទុកឲ្យកុមារជាអ្នកឆ្លើយ)*
៣. តើមានអ្វីខ្លះដែលអ្នកអាចធ្វើបានដើម្បីបង្ហាញថាអ្នកខ្វល់ខ្វាយពីគ្នាទៅវិញទៅមក?
*(ទុកឲ្យកុមារជាអ្នកឆ្លើយ)*

## ៧. ល្បែងកំសាន្ត “គ្រីស្ទបរិស័ទជួយគ្នាទៅវិញទៅមក”



សម្ភារៈដែលត្រូវការ៖ ក្រដាសមួយចំនួន

១. ចែកកុមារជា២ក្រុម ហើយឲ្យពួកគេឈរជាជួរតាមក្រុមនីមួយៗ

២. កុមារគ្រប់គ្នានៅក្នុងក្រុមត្រូវឈរ ដោយជើងទាំងពីរនៅលើ ក្រដា

៣. នៅពេលគ្រូរាប់ ១ ២ ៣ កុមារដែលនៅក្រោយគេត្រូវលើកជើងឡើងម្ខាង ហើយព្យាយាមបញ្ជូនក្រដាស់មួយសន្លឹក នោះមកឲ្យមេក្រុមដែលនៅមុខគេ។ បន្ទាប់មកមេក្រុមត្រូវដា ក់ក្រដាសនោះលើដីហើយ សមាជិកក្រុមនាំគ្នាផ្លាស់ទីតាមរហូតដល់ចុងម្ខាងទៀតនៃថ្នាក់រៀន។



៤. ប្រសិនបើជើងសមាជិកក្រុមណាម្នាក់ប៉ះដី (ដោយមិនបានជាន់លើក្រដាស) នោះក្រុមរបស់ពួក គេនឹងចាញ់ល្បែងនេះ។

៥. ក្រុមណាដែលអាចផ្លាស់ទីបញ្ជូនក្រដាសនោះដល់ចុងម្ខាងនៃថ្នាក់រៀនមុនគេនឹងឈ្នះល្បែងនោះ។

៦. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ដូចជាការដែលយើងមានការអត់ធ្មត់ និងជួយគ្នាទៅវិញទៅមកក្នុងការលេងល្បែងនេះ យើងក៏ត្រូវតែមានការអត់ធ្មត់ជានិច្ច ក្នុងការជួយដល់មនុស្សដែលនៅជុំវិញយើង។

## ៨. ខគម្ពីរចងចាំ

**កិច្ចការ ២៖៤២** *"អ្នកទាំងនោះក៏នៅតែព្យាយាមក្នុងសេចក្ដីបង្រៀនរបស់ពួកសាវ័ក ហើយក្នុងសេចក្ដីប្រកបគ្នា ព្រមទាំងការកាច់នំបុ័ង និងសេចក្ដីអធិស្ឋានផង។"*

## ៩. ហត្ថកម្ម «គ្រីស្ទបរិស័ទស្រលាញ់គ្នាទៅវិញទៅមក»





១. ចែកក្រដាសហត្ថកម្មឱ្យកុមារម្នាក់១សន្លឹក

២. ឲ្យកុមារតុបតែងនិងផាត់ពណ៌រូបភាពនោះ

៣. បត់ក្រដាសតាមបន្ទាត់ដាច់ ហើយកាត់តាមបន្ទាត់ជិតជុំវិញរូប

៤. លាតក្រដាសនោះហើយសរសេរថា **"ស្រលាញ់គ្នាទៅវិញទៅមក"** នៅក្នុងរូបបេះដូង។

៥. សូមរំលឹកកុមារថា គ្រីស្ទបរិស័ទត្រូវតែមើលថែគ្នាទៅវិញទៅមក។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
វាគឺមិនអាចទៅរួចនោះទេក្នុងការលូតលាស់ខាងឯសេចក្ដីជំនឿ - ឬក៏ជួយនរណាឲ្យមានជំនឿនោះ - ដោយគ្មានឥទ្ធិពលនៃសហគមន៍គ្រិស្ដបរិស័ទ និងសេចក្ដីស្រឡាញ់ពិតប្រាកដចំពោះអ្នកដទៃ។ សូមចំណាយពេលក្នុងការអាន **ទំនុកដំកើង ២៣**។ អានយឺតៗ ហើយឈប់រៀងរាល់មួយខម្ដង។ តើអ្នកសរសេរទំនុកដំកើងរៀបរាប់ពីជីវិតបែបណា? នេះគឺជាជីវិតដែលព្រះបានប្រទានឲ្យដល់អ្នកនិងអ្នកផ្សេងទៀតដែលអ្នកស្គាល់! តើអ្នកអាចជួយសម្រួលដល់ទំនាក់ទំនងជាមួយព្រះ, ផ្ដោតទៅលើអ្វីដែលព្រះចង់បានឬទេ? ទំនាក់ទំនងរបស់យើងជាមួយគ្រីស្ទបរិស័ទផ្សេងទៀត គឺឆ្លុះបញ្ចាំងពីទំនាក់ទំនង របស់យើងជាមួយព្រះផងដែរ។

## ហត្ថកម្ម - គ្រីស្ទបរិស័ទស្រលាញ់គ្នាទៅវិញទៅមក



១. តុបតែងនិងផាត់ពណ៌រូបភាព
២. បត់ក្រដាសតាមបន្ទាត់ដាច់ ហើយកាត់តាមបន្ទាត់ជិតជុំវិញរូប
៣. លាតក្រដាសនោះហើយសរសេរថា “**ស្រលាញ់គ្នាទៅវិញទៅមក**” នៅក្នុងរូបបេះដូង។
៤. សូមរំលឹកកុមារថា គ្រីស្ទបរិស័ទត្រូវតែមើលថែគ្នាទៅវិញទៅមក។




## ហត្ថកម្ម - គ្រីស្ទបរិស័ទស្រលាញ់គ្នាទៅវិញទៅមក

១. តុបតែងនិងផាត់ពណ៌រូបភាព
២. បត់ក្រដាសតាមបន្ទាត់ដាច់ ហើយកាត់តាមបន្ទាត់ជិតជុំវិញរូប
៣. លាតក្រដាសនោះហើយសរសេរថា “**ស្រលាញ់គ្នាទៅវិញទៅមក**” នៅក្នុងរូបបេះដូង។
៤. សូមរំលឹកកុមារថា គ្រីស្ទបរិស័ទត្រូវតែមើលថែគ្នាទៅវិញទៅមក។




